ឧទាហរណ៍ៈ

ថ្ងៃ ៨ កើត, ៨ រោច និង ថ្ងៃ ១៥ កើត, ១៥ រោច ឬ ថ្ងៃ ១៤ រោច ជាថ្ងៃឧបោសថសីល ។

ក) សំនួរ

វ៉ាគ៉់ ឬ ឃ្នាប មានទ្រង់ទ្រាយដូចម្ដេច? សម្រាប់ប្រើយ៉ាងណាខ្លះក្នុងការសរសេរ? បើគេមិនប្រើ ឃ្នាប គេយកអ្វីមកប្រើជំនួស? ចូរលើកឧទាហរណ៍មកមើល?

ខ) ចម្លើយ

* *

*

(៦) វត្ថុសញ្ញា (—)

វត្ថុសញ្ញា មានរូបសណ្ឋានជាៈ គំនូសវែងយ៉ាងនេះ (—)

សម្រាប់ប្រើក្នុងការសេរសេរបានច្រើនយ៉ាង, ដូចមានពោលតទៅនេះ ៖

ក) សម្រាប់ប្រើទៀតសេចក្ដីកន្ទប្រយោគ, សេចក្ដីនោះមានសារៈសំខាន់ខ្វះដែរ,

ឧទាហរណ៍: (សម្រាប់ប្រើក្នុងភាសាខ្មែរ)

បុរសម្នាក់បានឃើញពោរម្នាក់ មានពុកមាត់ស្រមូម, រោមខ្មៅទុកតែភ្នែក, កាន់កាំភ្លើងនៅដៃបួលមក – ក៏ភិតភ័យញ័រអស់ទាំងប្រាណ – រត់បួលទៅពួនសម្ងំក្នុងផ្ទះ ។

ឬ: បុរសពីរនាក់ – ឪពុកនិងកូន – នាំគ្នាទៅកាន ... ។

ឬថា: ពន្ធកាយរបស់មនុស្សមាន: ក្បាល – ដងខ្លួន – ដៃ – ជើង – សក់ – មុខ – ភ្នែក –

ប្រមុះ — បង្ក — ប្ដាល់ — ប្ញាស — ត្របៀក ។ (ទោះជាប្រើក្បៀសក៏បាន) ។

ឧទាហរណ៍ ទី ២: (សម្រាប់ប្រើក្នុងភាសាបាលី)

ឆិន្ន — ហត្ថ — យស្ស — សោ > ឆិន្នហត្ថោ (បុរិសោ) "(បុរស) មានដៃដាច់ហើយ" ។

១) សម្រាប់ប្រើគូសពីមុខលេខរៀង ពាក្យសេចក្ដីក្នុងសៀវភៅ, លក្ខន្តិកៈ, ប្រការ, មាត្រា ឬ អត្ថបទណាមួយ,

ឧទាហរណ៍:

១ — អំពីការគំនាប់ទង់ជាតិ . . . . . . . . ;

២ — អំពីការគោរពទង់ជាតិ . . . . . . . ,

៣ — អំពី . . . . . . . . . . . . . . ,

ឬ ប្រើចុចគូសពីមុខលេខយ៉ាងនេះ (.—) ក៏បាន,

ឧទាហរណ៍:

ប្រការ ១.— ស្ដីអំពី . . . . . . . . . . ;

ប្រការ ២.— . . . . . . . . . . . . ;

ឬថា:

មាត្រា ១.– . . . . . . . . . . . . . . . . ;

មាត្រា ២.– . . . . . . . . . . . . . . . . ;

គ) សម្រាប់ប្រើក្នុងពាក្យនិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក,

ឧទាហរណ៍:

– នាង! ឯងបានចូលរៀនហើយឬនៅ?

– នៅ ។

– ចុះប្អូននាង?

– ប្អូនខ្ញុំក៏ពុំទាន់បានចូលរៀនដែរ ។

ឃ) សម្រាប់ប្រើដាក់ខាងដើម ឬ ខាងចុងពាក្យគុណមួយ ដែលត្រូវគេបំពេញ តាមលំនាំសព្ទបន្ទាប់ខាងដើម ឬ ខាងចុង,

ឧទាហរណ៍:

យុទ្ធវិធី, — សាស្ត្រ (អានថា: យុទ្ធវិធី, យុទ្ធ-សាស្ត្រ);

សេចក្ដីសុខ, — ចំរើន (អានថា: សេចក្ដីសុខ, សេចក្ដីចំរើន);

បុព្វណ្ហសម័យ, សាយណ្ហ — (អានថា: បុព្វណ្ហ-សម័យ, សាយណ្ហសម័យ) ។

ង) សម្រាប់ប្រើដាក់ចុងបន្ទាត់ សំគាល់ស័ព្ទដែលសរសេរឬបោះពុម្ពដល់ចុងបន្ទាត់ហើយ ប៉ុន្តែមិនទាន់អស់ព្យាង្គនៅឡើយ ត្រូវអានភ្ជាប់ទៅនឹងព្យាង្គខាងដើមបន្ទាត់ជាលំដាប់,

ឧទាហរណ៍:

នគរវត្តជាប្រាសាទមួយល្អឆើតជាងគេក្នុងចំ–
ណោមនៃប្រាសាទទាំងឡាយនៅអង្គរ ...។

ប៉ុន្តែមិនត្រូវប្រើ វជ្ជសញ្ញា បែបនេះ ឲ្យខូចព្យាង្គនៃ

ស័ព្ទ, ដូចជា ... បើ—យ, សរសេ—រ ។ល។

យ៉ាងនេះទៀយ, ត្រូវប្រើតែនៅទីបំផុតព្យាង្គនៃស័ព្ទដែលជាពហុព្យាង្គ ។

ខ) សម្រាប់ប្រើគួសក្នុងការកត់ត្រាគោត្តនាម នឹងបកតិនាម,

ឧទាហរណ៍:

ឡុង-ប្រិយា, ឡុង-សោភ័ណា, ឡុង-សុគន្ធី, ឡុង-សុគន្ធារី ។

មានសញ្ញា ២ យ៉ាងទៀត ដែលលោកពប់បញ្ចូលក្នុងពួក វង្គសញ្ញា (—) នេះដែរ ព្រោះមានទ្រង់ទ្រាយដូចគ្នា ប្លែកគ្នាតែវិធីប្រើបន្តិចបន្តួច, ដូចមានពោលតទៅនេះ ៖

១) យតិភង្គ[១] ជាសញ្ញាមួយបែប មានរូបដូចវង្គសញ្ញា (—) នេះដែរ សម្រាប់ប្រើដាក់ត្រង់ចន្លោះ

(១) ហៅថា "សហសញ្ញា" ក៏បាន ប៉ុន្តែមិនសូវប្រើ ។

សង្កាត់ពាក្យមួយម៉ាត់ដែលផ្ដាច់ចេញដោយខ្លួនពីគ្នា ត្រង់ចន្លោះឃ្លាគាថា, កាព្យ, ឃ្លោង,

ឧទាហរណ៍: (ខាងភាសាបាលី)

ទុហេតុកាមគា សត្ត- បត្តាទ្វីស តិហេតុកា ។

ឧទាហរណ៍: (ខាងភាសាខ្មែរ)

ប្រាប់នេះបើប្រាថ្នា គួរឲ្យអស់មហា- ជនផង

ត្រង់ត្រាប់ . . . ។

សត្ត ទឹង បត្តាទ្វីស ត្រូវភ្ជាប់គ្នា មហា ទឹងជន ក៏ត្រូវភ្ជាប់គ្នាដែរ, បែរជាដកដាច់ពីគ្នាតាមឃ្លារបស់កាព្យ, ត្រូវប្រើគ្រឿងសញ្ញា (–) នេះ ជាសំគាល់ឲ្យដឹងថាជាពាក្យភ្ជាប់គ្នា, យ៉ាងនេះ ហៅថា "យតិភង្គ" ។

ឧទាហរណ៍ទី ២:

ស្រគត់អស់គិ- ត្រៃយអង្គអចិ- ន្ត្រៃយទ្រង់

ករុណា សព្វសត្វដាក់ដល់ មណ្ឌលសួគ៌ា គុណ

គាប់ជាតិជា ស្រួស្រែផលបុណ្យ . . . ;

ឬថា៖ ដ្បិតសីលជាយាន នាំរូបរួបបាន ចៀស ចាកបត្ថា- បាយបាបបានដល់ មណ្ឌលសួគ៌- ល័យសុះមហា- និព្វានសេដ្ឋ(១). . ។

២) នយសញ្ញា ជាសញ្ញាមួយបែប មានរូបដូច វង្កសញ្ញា (–) នេះដែរ, សម្រាប់ប្រើគូសក្រោមពាក្យ ដែលមានសេចក្តីដូចគ្នាពីលើមក ឬ សម្រាប់ប្រើគូសពី ក្រោមពាក្យដែលត្រូវទន្ទេញឲ្យចាំមាត់ ឬ ប្រើគូសក្រោម ពាក្យសំខាន់ណាមួយ ដើម្បីធ្វើពាក្យនុះឲ្យឃើញជាក់ ស្តែងឡើង,

ក) ប្រើគូសក្រោមពាក្យដែលមានសេចក្តីដូចគ្នាពី លើមក,

ឧទាហរណ៍៖

ថ្ងៃអាទិត្យ ៩ រោច ខែពិសាខ

(១) ច្បាប់សុភាសិត ។

ថ្ងៃ ច័ន្ទ ១០ កើត ខែពិសាខ

— អង្គារ ១១ — —

— ពុធ ១២ — —

— ព្រហស្បត៍ ១៣ — —

— សុក្រ ១៤ — —

— សៅរ៍ ១៥ — —

បើនឹងប្រើក្បៀសពីរ ( " ) ដូច្នេះក៏បាន ឬប្រើតួអក្សរ (–ដ–) នេះ ដោយសំគាល់សេចក្ដីថា " ដូចគ្នា " ដូច្នេះក៏បាន តាមចូលចិត្តប្រើ ។

១) សម្រាប់ប្រើគូសពីក្រោមពាក្យដែលត្រូវទន្ទេញឲ្យចាំមាត់,

ឧទាហរណ៍:

គុណនាមមាន ៣ យ៉ាងគឺ ៖ បកតិគុណនាម ១, វិសេសគុណនាម ១ និង អតិវិសេសគុណនាម ១ ។

ឥ) សម្រាប់ប្រើគូសពីក្រោមពាក្យសំខាន់ ដើម្បីធ្វើពាក្យនោះឲ្យឃើញជាក់ស្តែងឡើង ,

ឧទាហរណ៍ៈ

ព្រាហ្មណ៍គិតថា: "កូនទាំងឡាយរបស់អញមាន៤នាក់, អញនឹងឲ្យទ្រព្យ ជំនុំកូនទាំងឡាយ ៤ នាក់នោះ ដល់កូនម្នាក់" ។

( យតិភង្គ និង ឆយសញ្ញា ទាំង២ យ៉ាងដូចពោលមកហើយនេះ មានរូបជាគំនូសវែង (–) ដូចគ្នានឹង វង្ឍសញ្ញា ដែរ បែកគ្នាតែត្រង់វិធីប្រើបន្តិចបន្តួច, ដូច្នេះគួរយើងកំណត់ហៅថា "វង្ឍសញ្ញា" ដូចគ្នាទាំងអស់ក៏បាន ដើម្បីឲ្យងាយដល់ការអាន និង ការចំណាំ ) ។

ក) សំនួរ

វង្ឍសញ្ញា មានសណ្ឋានដូចជាអ្វី? សម្រាប់ប្រើបានយ៉ាងណា ខ្លះក្នុងការសរសេរ? ចូរលើកឧទាហរណ៍គ្រប់

ឲមកពន្យល់? មានសញ្ញាអ្វីទៀត ដែលប្រើដូចគ្នានឹង វជ្ឈុសញ្ញា នេះ? ចូរពាប់ឈ្មោះមកមើល? ក្នុងសញ្ញានីមួយៗ មានវិធីប្រើដូចម្ដេចខ្លះ? ចូរនាំយកសញ្ញាមួយម្ដងៗ មកអធិប្បាយជាឧទាហរណ៍ គ្រប់ៗ ទាំងអស់ឲ្យល្មមស្ដាប់បាន? សញ្ញាទាំង ២ យ៉ាងខាងក្រោយ បើយើងហៅថា “វជ្ឈុសញ្ញា” តែម្យ៉ាងបានដែរឬទេ?

១) ចម្លើយ

|   |
|---|
|   |

* *

*

... ... ... ... ... ... ... ... ... ... ...

## (៧) មច្ឆណ្ឌសញ្ញា[១] (...)

ខណ្ឌសញ្ញាមួយបែប មានរូបយ៉ាងនេះ (...)

(១) ហៅថា “ពងត្រី” ក៏បាន ។